**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន បាវហ្សាន់ អិនដាសស្ទ្រៀលខូអិលធីឌី**

# កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ វេលា ម៉ោង ៩:០០ នាទី ព្រឹក មានកិច្ចប្រជុំមួយនៅក្រុមហ៊ុន បាវហ្សាន់ អិនដាសស្ទ្រៀលខូអិលធីឌីមានអាសយដ្ឋានស្ថិតនៅភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដោយមានអ្នកស្រី YAN XIANXIAជានាយកក្រុមហ៊ុន បានបើកកិច្ចប្រជុំមួយជាមួយ អ្នកស្រី តាំងបូរី ជាប្រធានរដ្ឋបាល និង បងប្អូនដែលជាប្រតិភូបុគ្គលិក ចំនួន ៣ រូបផ្សេងទៀត ដែលតំណាងអោយកម្មករ កម្មការិនីសរុប ១៨៨ នាក់។

ជាកិច្ចចាប់ផ្តើមអ្នកស្រី YAN XIANXIAជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់បងប្អូនប្រតិភូមបុគ្គលិក ទាំងអស់ដែលបានចូលរួម និង បានបើកកិច្ចពិភាក្សាអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតនៅផ្នែកដេរនិងផ្នែកឃ្លាំង ចំនួន ១២២ នាក់ សម្រាប់រយៈពេល ១ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែ មិថុនា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៣ ដោយសារមិនមានការបញ្ជាទិញរបស់អតិថិជន។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមក ភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភ ជូនកម្មករនិយោជិតម្នាក់ៗចំនួន៣០ដុល្លារ ក្នុងកំឡុងពេលនៃការព្យួរនេះ និង បើកជូនបងប្អូនកម្មករ និយោជិតនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣។

កិច្ចពិភាក្សាបានបញ្ចប់ នៅវេលាម៉ោង ១០:៣០ នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល ក្រោមស្មាតីយោគយល់គ្នា និង ទទួលយក នូវស្មារតីនៃកិច្ចព្រមព្រៀងនេះ។

ថ្ងៃព្រហស្បតិ៍ ១៤ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

កណ្តាល ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣

**ភាគីទាំងពីរបានឯកភាព និង ផ្តិតមេដៃទុកជាភស្តុតាង**

**ប្រតិភូបុគ្គលិក** | **តំណាងក្រុមហ៊ុន**


អ៊ុច ស៊ីនឿន


វង្ស សម្បត្តិ


ម៉ុម លក្ខិណា



អ្នកស្រី YAN XIANXIA